TIÊNG Campuchia

**សំណួរផ្នែកការពាររុក្ខជាតិ (២០ សំណួរ)**

**ចំណេះដឹងទូទៅ (៦ សំណួរ)**

**១. ពង្រការ "ត្រូវទាំង៤" ដើម្បីប្រើប្រាស់ថ្នាំការពាររុក្ខជាតិឱ្យមានប្រសិទ្ធិភាពខ្ពស់គឺ៖**

ក) ត្រូវថ្នាំ ត្រូវពេល ត្រូវរបៀប ត្រូវកំហាប់ និងបរិមាណ

ខ) ត្រូវថ្នាំ ត្រូវបរិមាណ ត្រូវតំលៃ ត្រូវតាមការកំណត់

គ) ត្រូវមុខសញ្ញា ត្រូវរបៀប ត្រូវបរិមាណ ត្រូវកន្លែង

ឃ) ត្រូវម៉ាកថ្នាំ ត្រូវពេលកំណត់ ត្រូវក្បួនខ្នាត ត្រូវបរិមាណ

**២. ដើម្បីធានាសុវត្ថិភាពការងារនៅពេលបាញ់ថ្នាំការពាររុក្ខជាតិចាំបាច់៖**

ក) មានបំពាក់សម្ភារៈការពារសុវត្ថិភាពការងារ មិនទទួលទានចំណីអាហារ ពិសារបារី ក្នុងពេលកំពុងបាញ់ថ្នាំ

ខ) មិនត្រូវប្រើប្រាស់បំពង់បាញ់ថ្នាំដែលបែក ឬ ធ្លាយ

គ) មិនបាញ់បញ្ច្រាស់ទិសខ្យល់បក់ និងចៀសវាងកុំឲ្យថ្នាំប៉ះពាល់ដល់សរពាង្គកាយ

ឃ) ចំឡើយទាំង៣ខាងលើត្រូវទាំងអស់

**៣. តើថ្នាំព្យាបាលជម្ងឺមានធាតុសកម្ម *Hexaconazole* អាចព្យាបាលជម្ងឺណាលើដើមកៅស៊ូ?**

ក) ជម្ងឺប្រផេះស

ខ) ជម្ងឺផ្កាកុឡាប

គ) ជម្ងឺកូរីនែសប៉ូរ៉ា (Corynespora)

ឃ) ចំឡើយទាំង៣ខាងលើត្រូវទាំងអស់

**៤. ចូរអោយដឹងថា សញ្ញានៅលើសំបកវេចខ្ចប់ថ្នាំការពាររុក្ខជាតិ ១ប្រភេទ មានខ្សែបន្ទាត់ពណ៌ក្រហម គឺចង់បញ្ជាក់ថាជាប្រភេទថ្នាំ៖**

ក) ពុលយ៉ាងខ្លាំង

ខ) ពុលកំរិតខ្ពស់

គ) ពុលកំរិតមធ្យម

ឃ) ពុលកំរិតស្រាល

**៥. តើប្រភេទថ្នាំដែលមិនអាចលាយជាមួយនឹងទឹក មានសញ្ញានៅខាងចុងក្រោយបង្អស់ជាអ្វី?**

ក) BHN (WP)

ខ) ND (EC)

គ)DD (WSC)

ឃ) H (G)

**៦. តើសមាសធាតុណាក្នុងថ្នាំការពាររុក្ខជាតិ មានប្រសិទ្ធិភាពខ្ពស់បំផុត ចំពោះមុខសញ្ញាបង្ការ និង ព្យាបាលជម្ងឺ?**

ក) ធាតុសកម្ម
ខ) សមាសធាតុបន្ទាប់បន្សំ
គ) សារធាតុរំលាយ
ឃ) ចំឡើយទាំង៣ខាងលើខុសទាំងអស់

**ជម្ងឺ បូទ្រីយ៉ូឌីផ្លូឌីយ៉ា** (Botryodiplodia) (2 **សំណួរ**)

**៧. តើការបាញ់ថ្នាំព្យាបាលជម្ងឺបូទ្រីយ៉ូឌីផ្លូឌីយ៉ា Botryodiplodia ត្រូវអនុវត្តនៅរដូវណាក្នុងឆ្នាំ?**

ក) រដូវប្រាំង
ខ) រដូវភ្លៀង
គ) រដូវកៅស៊ូលាស់ស្លឹកថ្មី
ឃ) ចំឡើយទាំង៣ខាងលើត្រូវទាំងអស់

**៨. ទីតាំងបំផ្លាញចំបងរបស់ជម្ងឺបូទ្រីយ៉ូឌីផ្លូឌីយ៉ា Botryodiplodia នៅលើដើមកៅស៊ូគឺ**

ក) ស្លឹក
ខ) ខ្នែង
គ) មែក និង តួដើម
ឃ) ចំឡើយ ខ និង ចំឡើយ គ ត្រូវ

**ជម្ងឺជ្រុះស្លឹករដូវភ្លៀង, ជម្ងឺឆ្នូតខ្មៅ** (៣ **សំណួរ**)

**៩. តើកម្មករចៀរជ័រត្រូវអនុវត្តការងារអ្វី ដើម្បីបង្ការជម្ងឺឆ្នូតខ្មៅនៅរដូវភ្លៀង?**

ក) មិនធ្វើការចៀរជ័រនៅពេលផ្ទាំងចៀរនៅសើម អនុវត្តវិធានការដាក់របាំងការពារទឹកភ្លៀង
ខ) ធ្វើការចៀរជ័រត្រូវតាមបច្ចេកទេស និងកំចាត់ស្មៅចង្រៃ
គ) ធ្វើអនាម័យផ្ទាំងចៀរអោយបានជាប្រចាំ លាបថ្នាំបង្ការជម្ងឺលើផ្ទាំងចៀរដោយយកចិត្តទុកដាក់
ឃ) ចំឡើយទាំង៣ខាងលើត្រូវទាំងអស់

**១០. តើការចៀរឫសក្នុងរដូវភ្លៀង នឹងបណ្តាលអោយកើតជម្ងឺអ្វី?**

ក) ជម្ងឺជ្រុះស្លឹករដូវភ្លៀង
ខ) ជម្ងឺស្ងួតផ្ទាំងចៀរ
គ) ជម្ងឺប្រផេះស
ឃ) ជម្ងឺឆ្នូតខ្មៅ

**១១. តើជម្ងឺណាមានលក្ខណៈបង្កការកកើតជម្ងឺ ដូចគ្នានឹងជម្ងឺជ្រុះស្លឹករដូវភ្លៀងក្នុងចំការកៅស៊ូ អាជីវកម្ម?**

ក) ជម្ងឺឆេះរលួយកន្ទុយស្លឹក
ខ) ជម្ងឺផ្កាកុឡាប
<u>គ) ជម្ងឺឆ្នូតខ្មៅ</u>
ឃ) ជម្ងឺប្រផេះ

**ជម្ងឺប្រផេះ និង ជម្ងឺឆេះរលួយកន្ទុយស្លឹក ( ៤ សំណួរ )**

**១២. តើការបាញ់ថ្នាំព្យាបាលជម្ងឺប្រផេះ និង ជម្ងឺឆេះរលួយកន្ទុយស្លឹក គប្បីបាញ់ថ្នាំនៅផ្នែកណារបស់ ដើមកៅស៊ូ?**

<u>ក) ស្រទាប់ស្លឹកខ្ចី</u>
ខ) ស្រទាប់ស្លឹកចាស់
គ) តួដើម
ឃ) ជុំវិញគល់

**១៣. តើជាទូទៅជម្ងឺប្រផេះបំផ្លាញលើចំការកៅស៊ូប្រភេទណា?**

ក) ថ្នាលពូជ ថ្នាលបណ្ដុះកូនកៅស៊ូ
ខ) ចំការមិនទាន់ឲ្យផល
គ) ចំការអាជីវកម្ម
<u>ឃ) ចំឡើយទាំង៣ខាងលើត្រូវទាំងអស់</u>

**១៤. តើប្រភេទជម្ងឺតែងតែកើតមានក្នុងចំការកៅស៊ូអាជីវកម្ម នៅរដូវលាស់ស្លឹកថ្មីជារៀងរាល់ឆ្នាំ ជាជម្ងឺអ្វី?**

ក) ជម្ងឺផ្កាកុឡាប
ខ) ជម្ងឺអុជភ្នែកចាប
<u>គ) ជម្ងឺប្រផេះ</u>
ឃ) ជម្ងឺស្ងួតផ្ទាំងចៀរ

**១៥. តើជម្ងឺប្រផេះបំផ្លាញយ៉ាងធ្ងន់ធ្ងរ ទៅលើផ្នែកណារបស់ដើមកៅស៊ូ?**

ក) តួដើម និងមែកមានសំបកឈានទៅពណ៌ត្នោត
<u>ខ) ស្លឹកខ្ចី និងផ្កា</u>
គ) ឫស
ឃ) ផ្ទាំងចៀរ

**ជម្ងឺផ្កាកុឡាប** (២ សំណួរ)

**១៦. តើចំពោះជម្ងឺផ្កាកុឡាប គេត្រូវបាញ់ថ្នាំនៅកន្លែងណាទើបត្រឹមត្រូវ?**

ក) បាញ់ទៅលើស្លឹក

ខ) បាញ់ជុំវិញគល់

<u>គ) បាញ់អោយជោកសព្វស្នាមជម្ងឺ</u>

ឃ) បាញ់ទៅលើខ្នែងខ្ចីមានពណ៌បៃតង

**១៧. តើជម្ងឺផ្កាកុឡាបកើតមាន និងបំផ្លាញយ៉ាងធ្ងន់ ទៅលើដើមកៅស៊ូមានអាយុប៉ុន្មានឆ្នាំ?**

ក) ពី ១ឆ្នាំ ទៅ៣ឆ្នាំ

<u>ខ) អាយុពី ៣ឆ្នាំ ទៅ ៨ឆ្នាំ</u>

គ) អាយុពី ៨ឆ្នាំ ទៅ១៥ឆ្នាំ

ឃ) អាយុលើសពី ១៥ឆ្នាំ

**ជំងឺក្រូរីនេសប៉ូរ៉ា** Corynespora (៣ **សំណួរ**)

**១៨. តើជម្ងឺក្ររីនេសប៉ូរ៉ា (Corynespora) បំផ្លាញទៅលើផ្នែកណារបស់ដើមកៅស៊ូ?**

ក) ស្លឹក

ខ) ទងស្លឹក

គ) ខ្នែង

<u>ឃ) ចំឡើយទាំង៣ខាងលើ ត្រូវទាំងអស់</u>

**១៩. តើជម្ងឺក្ររីនេសប៉ូរ៉ា (Corynespora) អាចកើតមាន និង បំផ្លាញដល់ចំការកៅស៊ូនៅរដូវណាក្នុងឆ្នាំ?**

ក) រដូវភ្លៀងធ្លាក់យូរ

ខ) រដូវប្រាំង

គ) រដូវដើមកៅស៊ូលាស់ស្លឹកថ្មី

<u>ឃ) ពេញមួយឆ្នាំ</u>

**២០. តើជម្ងឺក្ររីនេសប៉ូរ៉ាបំផ្លាញចំពោះដំណាក់កាលលូតលាស់ណារបស់ដើមកៅស៊ូ?**

ក) កូនកៅស៊ូនៅថ្នាលបណ្តុះ

ខ) ដើមកៅស៊ូក្នុងដំណាក់កាលមិនទាន់អោយផល

គ) ដើមកៅស៊ូចាស់

<u>ឃ) គ្រប់ដំណាក់កាលលូតលាស់របស់ដើមកៅស៊ូ</u>

## សំណួរប្រមូលផលជ័រ ( ៣៧ សំណួរ )

## ការកំណត់ទូទៅ ( ៣ សំណួរ)

**២១. តើជាទូទៅចំការកៅស៊ូមានលក្ខណៈដូចម្តេចទើបអាចដាក់អោយចៀរជ័របាន?**

ក) មានអត្រាលើសពី ៧០% ដើមកៅស៊ូមានទំហំតួដើមចាប់ពី ៥០ស.ម ឡើងទៅ និងសំបកត្រូវមានកំរាស់ចាប់ពី ៦ម.ម វាស់នៅកំពស់១ម៉ែត្រ ឃ្លាតពីដី
ខ) គ្រាន់តែមានរយៈពេលថែទាំនៃដំណាក់កាលមិនទាន់អោយផល ពី៦ ទៅ ៧ឆ្នាំ គឺបានហើយ
គ) ៥០% ដើមកៅស៊ូមានទំហំតួដើម ៥០ស.ម
ឃ) ចំឡើយទាំង៣ខាងលើខុសទាំងអស់

**២២. តើមូលហេតុអ្វីត្រូវផ្លាស់ប្តូរទិសចាប់ផ្តើមធ្វើការចៀរ នៅផែនចៀរបន្ទាប់?**

ក) ដើម្បីដើមកៅស៊ូក្នុងពនចៀរមានរយៈពេលហូរជ័រប្រហែលគ្នា ទិន្នផលជ័រប្រមូលបានច្រើន
ខ) សម្រួលដល់កម្មករអាចគ្រប់គ្រងពនចៀររបស់ខ្លួនកាន់តែល្អប្រសើរឡើង
គ) ចៀសវាងកុំអោយដើមកៅស៊ូត្រូវស្ងួតមុខចៀរ
ឃ) ងាយស្រួលក្នុងការត្រួតពិនិត្យបញ្ហាលួចជ័រ

**២៣. តើតាមបទដ្ឋានបច្ចេកទេសដំណាំកៅស៊ូឆ្នាំ២០១២ វដ្តប្រមូលផលជ័រកៅស៊ូនៅប្រទេសវៀតណាម ត្រូវបានកំណត់មានរយៈពេលប៉ុន្មានឆ្នាំ?**

ក) ២០ឆ្នាំ
ខ) ២២ឆ្នាំ
គ) ២៥ឆ្នាំ
ឃ) ៣០ឆ្នាំ

## ប្រព័ន្ធចៀរជ័រ ( ៧ សំណួរ )

**២៤. តើប្រព័ន្ធចៀរជ័រមានន័យដូចម្តេច?**

ក) ជាចំនួនថ្ងៃធ្វើការចៀរជ័រជាក់ស្តែងក្នុងឆ្នាំ
ខ) ជាការរួមផ្សំរវាងប្រវែងមុខចៀរ សង្វាក់ចៀរ និងការប្រើប្រាស់ថ្នាំរំញោចសម្រាប់ការប្រមូលផលជ័រកៅស៊ូ
គ) ជាមូលដ្ឋានដើម្បីគណនាប្រាក់ឈ្នួលអោយកម្មករចៀរជ័រ
ឃ) ជាកាកំណត់មួយរបស់រដ្ឋ

**២៥. ចូររៀបរាប់អំពីអត្ថន័យសញ្ញាសន្ទស្សន៍ប្រព័ន្ធចៀរជ័រ S/4U d4 6d/7.ET 2,5% La 7/y**

ក) ចៀរ ១/៤ ជុំតួដើម ១អាទិត្យចៀរ៤ថ្ងៃ ឈប់សម្រាក១ថ្ងៃ ប្រើប្រាស់ថ្នាំរំញោច Ethephon ២,៥% លាប៧ដងក្នុង១ឆ្នាំ

ខ) ចៀរ១/៤ជុំតួដើម មុខចៀរផ្កាប់ ចៀរមួយថ្ងៃឈប់សម្រាក៣ថ្ងៃបន្ទាប់ ចៀរ៦ថ្ងៃឈប់សំរាក១ថ្ងៃ ធ្វើការចៀរជ័រគួបផ្សំជាមួយនឹងការប្រើប្រាស់ថ្នាំរំញោច Ethephon ២,៥% លាបទៅលើចង្អូរមុខចៀរ ដោយមិនត្រូវបកជ័រមុខ លាប៧ដងក្នុង១ឆ្នាំ

គ) ចៀរពាក់កណ្តាលជុំតួដើមកៅស៊ូ តាមវេនចៀរ A, B, C, D

ឃ) ចៀរពាក់កណ្តាលជុំតួដើមកៅស៊ូក្នុង៣ថ្ងៃបន្តបន្ទាប់ រួចឈប់សំរាក១ថ្ងៃ ចៀរជ័រដោយមានលាបថ្នាំរំញោច Ethephon ២,៥%

**២៦. ចូររៀបរាប់អំពីអត្ថន័យសញ្ញាសន្ទស្សន៍ប្រព័ន្ធចៀរជ័រ S/2 d3 6d/7.ET 2,5% Pa 4/y**

ក) ចៀរពាក់កណ្តាលជុំតួដើម ១អាទិត្យចៀរ៣ថ្ងៃ ឈប់សម្រាក១ថ្ងៃ ប្រើប្រាស់ថ្នាំរំញោច Ethephon ២,៥% លាប៤ដងក្នុង១ឆ្នាំ

ខ) ចៀរពាក់កណ្តាលជុំតួដើមកៅស៊ូ តាមវេនចៀរ A, B, C

គ) ចៀរពាក់កណ្តាលជុំតួដើមកៅស៊ូ មុខចៀរផ្ងារ ចៀរ១ថ្ងៃឈប់សំរាក២ថ្ងៃបន្ទាប់ ចៀរ៦ថ្ងៃឈប់សំរាក១ថ្ងៃ ធ្វើការចៀរជ័រគួបផ្សំជាមួយនឹងការប្រើប្រាស់ថ្នាំរំញោច Ethephon ២,៥% លាបទៅលើផ្ទាំងចៀរសំបកដុះថ្មីឡើងវិញ លាប៤ដងក្នុង១ឆ្នាំ

ឃ) ចៀរពាក់កណ្តាលជុំតួដើមក្នុង៣ថ្ងៃបន្តបន្ទាប់ រួចឈប់សម្រាក១ថ្ងៃ ចៀរជ័រដោយមានលាបថ្នាំរំញោច Ethephon ២,៥%

**២៧. ចូររៀបរាប់អំពីអត្ថន័យសញ្ញាសន្ទស្សន៍ប្រព័ន្ធចៀរជ័រ S/2 d6 6d/7.ET 2,5% Pa 8-10/y**

ក) ចៀរពាក់កណ្តាលជុំតួដើម មុខចៀរផ្ងារ ១អាទិត្យចៀរ៥ថ្ងៃ ឈប់សំរាក១ថ្ងៃ ប្រើប្រាស់ថ្នាំរំញោច Ethephon ២,៥% លាបចំនួនពី ០៨ ទៅ ១០ដងក្នុង១ឆ្នាំ

ខ) ចៀរពាក់កណ្តាលជុំតួដើមកៅស៊ូ មុខចៀរផ្ងារ ចៀរ០១ថ្ងៃឈប់សំរាក០៥ថ្ងៃបន្ទាប់ កម្មករធ្វើការចៀរ៦ថ្ងៃ ឈប់សម្រាក១ថ្ងៃ ធ្វើការចៀរជ័រគួបផ្សំជាមួយនឹងការប្រើប្រាស់ថ្នាំរំញោច Ethephon ២,៥% លាបទៅលើផ្ទាំងចៀរសំបកដុះថ្មីឡើងវិញ លាបចំនួនពី០៨ ទៅ ១០ដង ក្នុង១ឆ្នាំ

គ) ចៀរពាក់កណ្តាលជុំតួដើមកៅស៊ូ តាមវេនចៀរ A, B, C, D, E និង F.

ឃ) ចៀរពាក់កណ្តាលជុំតួដើមកៅស៊ូក្នុង០៦ថ្ងៃបន្តបន្ទាប់ រួចឈប់សម្រាក១ថ្ងៃ ធ្វើការចៀរជ័រដោយមានលាបថ្នាំរំញោច Ethephon ២,៥%

**២៨. ផ្អែកតាមទ្រឹស្តី ប្រព័ន្ធចៀរជ័រមានកំរិតចៀរប្រហាក់ប្រហែល១០០%គឺ៖**

ក) S/2 d3

ខ) S d4

គ) S/2 d2

ឃ) មានតែចំឡើយ ខ និង ចំឡើយ គ គឺត្រូវ

**២៩. តើផ្អែកតាមបទដ្ឋានបច្ចេកទេសដំណាំកៅស៊ូឆ្នាំ២០១២ វិធានការណាដែលល្អប្រសើរបំផុត ដើម្បី បង្កើនទិន្នផលជ័រនៅពេលដើមកៅស៊ូមានអាយុចៀរដល់ ១១ឆ្នាំ?**

ក) បន្តការចៀរលើសំបកកំណើត ដែលទាបនៅខាងក្រោម

ខ) ចៀរផ្អាប់ដោយមានការត្រួតពិនិត្យ ដើម្បីចៀរស្រទាប់សំបកកំណើត ដែលខ្ពស់នៅខាងលើ

គ) ចៀរអោចម៍ពន្លាកក្រាស់ ដើម្បីអោយឆាប់អស់សំបកកំណើតដែលទាបនៅខាងក្រោម

ឃ) ចំឡើយទាំង៣ខាងលើ ត្រូវទាំងអស់

**៣០. តើការចៀរផ្អាប់ដោយមានការត្រួតពិនិត្យត្រូវបានអនុវត្តនៅពេលណា?**

ក) ដល់ឆ្នាំចៀរទី១១ ដើម្បីចៀរស្រទាប់សំបកកំណើត ដែលខ្ពស់នៅខាងលើ

ខ) នៅពេលស្រទាប់សំបកដុះថ្មីឡើងវិញនៅខាងក្រោម កើតកំពឹកកំពក និងគុណភាពអន់

គ) នៅពេលស្រទាប់សំបកដុះថ្មីឡើងវិញនៅខាងក្រោមអោយទិន្នផលជ័រតិច ឬ ស្ងួតផ្ចាំងចៀរ

ឃ) ចំឡើយទាំង៣ខាងលើត្រូវទាំងអស់

**សង្វាក់ចៀរ (៣ សំណួរ)**

**៣១. សង្វាក់ចៀរមានន័យថា៖**

ក) ចន្លោះពេលរវាងការចៀរជ័រ ២លើក ដែលបន្តបន្ទាប់គ្នា

ខ) ចំងាយដែលកម្មករត្រូវផ្លាស់ប្តូរទីកន្លែង ពេលធ្វើការចៀរជ័រ

គ) ចំនួនដើមចៀរដែលបែងចែកអោយទៅកម្មករចៀរជ័រសំរាប់វេនចៀរមួយ

ឃ) ការរួមផ្សំរវាងប្រវែងមុខចៀរ និង កំរិតចៀរ

**៣២. តើការចៀរដោយបង្កើនសង្វាក់ចៀរ នឹងជះឥទ្ធិពលអ្វីដល់ដើមកៅស៊ូ?**

ក) នឹងបង្កអោយបាត់តុល្យភាពនៃលក្ខណៈជីវសាស្ត្រក្នុងការផ្តល់ទឹកជ័រ និងបង្កើតទឹកជ័រឡើងវិញរបស់ដើមកៅស៊ូ ករណីស្ថានភាពនេះអូសបន្លាយនឹងធ្វើអោយដើមកៅស៊ូស្ងួតផ្ចាំងចៀរ

ខ) នឹងបង្កអោយដើមកៅស៊ូជ្រុះស្លឹកនៅរដូវរងារឆាប់ជាងធម្មតា

គ) ភាពធន់ទ្រាំនឹងជម្ងឺរបស់ដើមកៅស៊ូត្រូវថយចុះគួរអោយកត់សំគាល់

ឃ) ករណីបាក់បែក ដួលរលំរបស់ដើមកៅស៊ូងាយកើតមានក្នុងកំរិតខ្ពស់ជាងធម្មតា

**៣៣. តើដើម្បីដោះស្រាយបញ្ហាខ្វះកម្លាំងកម្មករ ក៏ដូចជាការបង្កើនផលិតភាពរបស់កម្មករ អាចអនុវត្តប្រព័ន្ធចៀរជ័រមួយណាខាងក្រោមនេះ?**

ក) ចៀរតាមសង្វាក់ចៀរ d2 (២ថ្ងៃចៀរម្តង) និងបង្កើនចំនួនលើកធ្វើរំញោចសមស្រប

ខ) រក្សាសង្វាក់ចៀរ d3 ដដែល

គ) អនុវត្តការចៀរជ័រតាមសង្វាក់ចៀរ d4 d5 ឬ d6 គួបផ្សំជាមួយនឹងការបង្កើនចំនួនលើកធ្វើរំញោចជំនួសការចៀរតាមសង្វាក់ចៀរ d3

ឃ) បន្ថយចំនួនដើមចៀរសម្រាប់ពនចៀរ

**ការធ្វើរំញោច (៧ សំណួរ)**

**៣៤. ហេតុអ្វីករណីធ្វើរំញោច ត្រូវចាត់ចែងការសារជ័រម្តងទៀតនៅពេលល្ងាច?**

ក) ធ្វើរំញោចដើម្បីអូសបន្លាយរយៈពេលហូរជ័រ
ខ) ចៀសវាងកុំអោយជ័រហៀរចេញពីចាន ក្នុងករណីមានភ្លៀងធ្លាក់នៅពេលល្ងាច
គ) ចំឡើយ ក និង ចំឡើយ ខ ត្រូវទាំងពីរ
ឃ) ចំឡើយ ក និង ចំឡើយ ខ ខុសទាំងពីរ

**៣៥. ចូរអោយដឹងថា៖ ដើម្បីអោយដើមមានប្រតិកម្មវិជ្ជមានចំពោះថ្នាំរំញោច និងអោយទិន្នផលជ័រខ្ពស់ បំផុត គេត្រូវលាបថ្នាំរំញោចមុនពេលធ្វើការចៀរលើកបន្ទាប់ប៉ុន្មានម៉ោង?**

ក) ១២ - ២៤ម៉ោង
ខ) ២៤ - ៤៨ម៉ោង
គ) ៤៨ - ៧២ម៉ោង
ឃ) ៧២ - ៩៦ម៉ោង

**៣៦. តើចំពោះតំបន់មានរដូវវស្សា និងរដូវប្រាំង ដោយឡែកពីគ្នាយ៉ាងច្បាស់លាស់ (តំបន់ខាងកើត និង តំបន់ខ្ពង់រាបខាងលិចភាគខាងត្បូង...) រដូវដែលសមស្របដើម្បីធ្វើរំញោច គឺនៅខែណាខ្លះ?**

ក) ខែ ១, ៦, ៧, ១០, ១១, ១២
ខ) ខែ ៥ ,៦, ៧, ១០, ១១, ១២
គ) ខែ ១, ៥, ៩, ១០, ១១, ១២
ឃ) ខែ ៣, ៥, ៩, ១០, ១១, ១២

**៣៧. តើចំពោះដើមកៅស៊ូ (ដាំនៅតំបន់ឆ្នេរសមុទ្រនៃភាគកណ្តាល និងតំបន់ព្រៃភ្នំនៃភាគខាងជើង) រយៈពេលណាដែល សមស្របដើម្បីធ្វើរំញោច គឺនៅខែណាខ្លះ?**

ក) ខែ ១, ៦, ៧, ១០, ១១, ១២
ខ) ខែ ៥ ,៦, ៧, ១០, ១១, ១២
គ) ខែ ៥ ,៦, ៧, ៨, ៩ និង ១០
ឃ) ខែ ២, ៥, ៩, ១០, ១១, ១២

**៣៨. តើបច្ចុប្បន្នវិធីសាស្ត្រធ្វើរំញោចណាត្រូវបានអនុវត្តជាទូទៅសម្រាប់មុខចៀរថ្មារ ដែលងាយ ស្រួលអនុវត្ត និង មានប្រសិទ្ធិភាពខ្ពស់ក្នុងការធ្វើរំញោច?**

ក) La (លាបទៅលើមុខចៀរដោយមិនបកជ័រមុខ)

ខ) Pa (លាបទៅលើសំបកដុះថ្មីឡើងវិញ ដែលកៀកជិតមុខចៀរ)
គ) La (លាបទៅលើសំបកដែលកោសសំអាត)
ឃ) La (លាបទៅលើមុខចៀរដោយមានបកជ័រមុខ)

**៣៩. តើបច្ចុប្បន្នវិធីសាស្រ្តធ្វើរំញោចណាត្រូវបានអនុវត្តជាទូទៅសម្រាប់មុខចៀរផ្កាប់ ដែលងាយ ស្រួលអនុវត្ត និង មានប្រសិទ្ធិភាពខ្ពស់ក្នុងការធ្វើរំញោច?**

ក) La (លាបទៅលើមុខចៀរដោយមិនបកជ័រមុខ)
ខ) Pa (លាបទៅលើសំបកដុះថ្មីឡើងវិញ ដែលកៀកជិតមុខចៀរ)
គ) La (លាបទៅលើសំបកដែលកោសសំអាត)
ឃ) La (លាបទៅលើមុខចៀរដោយមានបកជ័រមុខ)

**៤០. តើតាមបទដ្ឋានបច្ចេកទេសបំពេញបន្ថែមឆ្នាំ២០១៧ ចំនួនលើកធ្វើរំញោចត្រូវផ្អែកតាមកត្តាទាំងឡាយណាខាងក្រោមនេះ ?**

ក) ប្រតិកម្មពីការធ្វើរំញោចនៃប្រភេទពូជក្លូន
ខ) អាស្រ័យទៅតាមសង្វាក់ចៀរ
គ) អាស្រ័យទៅតាមអាយុចៀរ
ឃ) ចំឡើយទាំង៣ ក ខ និង គ ត្រូវទាំងអស់

## ការបែងចែកសំបកចៀរ និង ចែករានចៀរ ( ៤ សំណួរ )

**៤១. តើអត្ថន័យសញ្ញាសន្មតផ្ទាំងចៀរ BO-1 គឺជាអ្វី?**

ក) តួអក្សរ B គឺជាសញ្ញាសន្មតផ្ទាំងចៀរទាបនៅខាងក្រោម
ខ) តួអក្សរ O គឺជាសញ្ញាសន្មតសំបកកំណើត
គ) លេខ១ គឺជាផ្ទាំងចៀរទី១
ឃ) ចំឡើយខាងលើត្រូវទាំងអស់

**៤២. តើអត្ថន័យសញ្ញាសន្មតផ្ទាំងចៀរ HO-4 គឺជាអ្វី?**

ក) ចៀរនៅផ្ទាំងចៀរខ្ពស់នៅខាងលើ សំបកកំណើត ផ្ទាំងចៀរទី៤
ខ) ចៀរលើផ្ទាំងចៀរទាបនៅខាងក្រោម សំបកកំណើត ផ្ទាំងចៀរទី៤
គ) ចៀរលើផ្ទាំងចៀរខ្ពស់នៅខាងលើ សំបកដុះថ្មីឡើងវិញ ផ្ទាំងចៀរទី៤
ឃ) ចំឡើយទាំង៣ខាងលើត្រូវទាំងអស់

**៤៣. ជាទូទៅការចែកចំនួនដើមចៀរសំរាប់រានចៀរនិមួយៗ ត្រូវផ្អែកទៅលើកត្តា៖**

ក) លក្ខណៈសណ្ឋានភាពដីរបស់ចំការ

ខ) ដង់ស៊ីតេដើមចៀរ
គ) អាយុដើម ស្ថានភាពសំបកចៀរ ប្រព័ន្ធចៀរជ័រត្រូវបានអនុវត្ត
<u>ឃ) ចំឡើយទាំង៣ខាងលើត្រូវទាំងអស់</u>

**៤៤. តើចំពោះតំបន់ដែលខ្វះកម្លាំងកម្មករចៀរជ័រ ការជ្រើសយកគម្រោងការណា ដែលមានចែង ក្រោមនេះត្រូវបានចាត់ទុកថា៖ មានប្រសិទ្ធិភាព មិនប៉ះពាល់ខ្លាំងដល់លទ្ធផលពីការធ្វើអាជីវកម្ម ប៉ុន្តែអាចបង្កើនផលិតភាពពលកម្ម និងបង្កើនប្រាក់ចំណូលសម្រាប់កម្មករចៀរជ័រ?**

ក) ទុកអោយជ័រកកដោយខ្លួនឯងនៅតាមឡត់ ចែកដើមចៀរសម្រាប់កានចៀរនិមួយៗចំនួន ៧៥០ដើម ក្នុងលក្ខខ័ណ្ឌមានប្រើប្រាស់របាំងការពារទឹកភ្លៀងសមស្រប សម្រាប់ផ្ទាំងចៀរ និងចានត្រងជ័រ
ខ) អនុវត្តប្រព័ន្ធចៀរតាមសង្វាក់ចៀររង្វើល d4, d5 ឬ d6 និងធ្វើរំញោចក្នុងកំរិតសមស្របទៅនឹងលក្ខខ័ណ្ឌមានប្រើប្រាស់របាំងការពារទឹកភ្លៀងសមស្រប សម្រាប់ផ្ទាំងចៀរ និងចានត្រងជ័រ
<u>គ) ចំឡើយ ក និងចំឡើយ ខ ខាងលើ ត្រូវទាំងពីរ</u>
ឃ) ចំឡើយ ក និងចំឡើយ ខ ខាងលើ ខុសទាំងពីរ

**ការបំពាក់សម្ភារៈ** ( **៥ សំណួរ** )

**៤៥. តើហេតុអ្វីពេលសារជ័រត្រូវប្រើប្រដាប់គៀរជ័រ?**

ក) ប្រើប្រដាប់គៀរជ័រដើម្បីទប់ស្កាត់ការឆាប់កកជ័រក្នុងចាន
<u>ខ) ប្រើប្រដាប់គៀរដើម្បីប្រមែប្រមូលអោយអស់ទឹកជ័រក្នុងចាន</u>
គ) ប្រើប្រដាប់គៀរដើម្បីបង្កើនបរិមាណជ័រស្ងួត
ឃ) ចំឡើយទាំង៣ខាងលើត្រូវទាំងអស់

**៤៦. តើតម្រូវការនៅពេលប្រើប្រាស់ពន្លាកចៀរជ័រមានអ្វីខ្លះ?**

ក) ពន្លាកត្រូវធ្វើអំពីដែកថែបមិនច្រេះ រឹងមាំ
ខ) ពន្លាកចៀរត្រូវមានដងធ្វើអំពីឈើរឹងមាំ សំរូលដល់កាយវិការចៀរជ័រ
<u>គ) ពន្លាកត្រូវធ្វើអំពីដែកថែបមានគុណភាពល្អ រក្សាអោយបានស្អាតបាត សំលៀងអោយមុតជានិច្ច ពេលណាមិនត្រូវការប្រើប្រាស់ត្រូវគ្របស្នែពន្លាកអោយជិត ដើម្បីការពារសុវត្ថិភាព</u>
ឃ) ពន្លាកត្រូវចៀរបានទាំងមុខចៀរផ្ងារ ព្រមទាំងមុខចៀរផ្កាប់

**៤៧. សម្ភារៈបំពាក់សំរាប់ដើមចៀររួមមាន៖**

ក) លួសកងទ្រចាន ស្លាបព្រាបង្ហូរជ័រ និង ចាន
ខ) របាំងការពារទឹកភ្លៀង
គ) គម្របការពារទឹកភ្លៀង ឬ គម្របចាន
<u>ឃ) ចំឡើយទាំង៣ខាងលើត្រូវទាំងអស់</u>

**៤៨. ហេតុអ្វីត្រូវដាក់របាំងការពារទឹកភ្លៀងសម្រាប់ដើមចៀរ?**

ក) ដើម្បីទប់ស្កាត់ និងកាត់បន្ថយទឹកភ្លៀងហូរពីលើស្លឹកចុះមកតួដើម ធ្វើអោយសើមផ្ទាំងចៀរ

ខ) ការពារផ្ទាំងចៀរ និង មុខចៀរកុំអោយសើម ដើម្បីអាចចៀរជ័របានតាមធម្មតានៅរដូវភ្លៀង

គ) កាត់បន្ថយការបាត់បង់ទិន្នផលជ័រក្នុងរដូវភ្លៀង

<u>ឃ) ចំឡើយទាំង៣ខាងលើត្រូវទាំងអស់</u>

**៤៩. តើករណីនត្រូវការចៀរដើម្បីទាញយកអោយអស់ជ័រ សំភារៈចំពាក់សំរាប់កម្មករម្នាក់មានអ្វី?**

ក) ពន្លាកចៀរមានដងវែងដែលអាចកែសម្រួលប្រវែងបាន ខ្សែតម្រង់ទឹកជ័រធ្វើពីអំបោះ ឬ នីឡុង

ខ) ឧបករណ៍សម្រាប់ការលាបថ្នាំរំញោចនៅទីតាំងដែលខ្ពស់នៅខាងលើ

គ) ឧបករណ៍បញ្ចុះស្លាបព្រាសម្រាប់ទីតាំងខ្ពស់នៅខាងលើ ស្លាបព្រាប្រវែង ១០ស.ម មានចោះរន្ធ

<u>ឃ) ចំឡើយទាំង៣ខាងលើត្រូវទាំងអស់</u>

**ការគូសចែកមុខចៀរ (៦ សំណួរ)**

**៥០. ចំពោះការចៀរផ្កាប់ដោយមានការត្រួតពិនិត្យ កំពស់បើកមុខត្រូវរៀបចំអោយឃ្លាតពីដី៖**

<u>ក) ពី ១,៣ម៉ែត្រ ទៅ ២ម៉ែត្រ</u>

ខ) ពី ២ម៉ែត្រ ឡើងទៅ

គ) អាស្រ័យទៅតាមកាលបរិច្ឆេទដាក់អោយបើកមុខចៀរ និង លក្ខណៈពិសេសរបស់ពូជ ដើម្បីរៀបចំអោយមានកំពស់សមស្របចាប់ពី ១,៣ម៉ែត្រ ឡើងទៅ

ឃ) ចំឡើយទាំង៣ខាងលើខុសទាំងអស់

**៥១. តម្រូវការជាមូលដ្ឋានដើម្បីចៀសវាងកុំអោយជ័រហៀររាលដាលចុះមកផ្ទាំងចៀរពេលចៀរផ្កាប់គឺ៖**

ក) មុខចៀរផ្កាប់ត្រូវអោយមានចំណោត ៤៥ដឺក្រេ

ខ) មុខចៀរផ្កាប់ត្រូវមានរាងផតស្នូកបាយជ្រូក

គ) ធ្វើចង្អូរទម្រពីខាងក្រោមមុខចៀរផ្កាប់ ដើម្បីតម្រង់ទឹកជ័រ កុំអោយហៀររាលដាលចុះមកខាងក្រោមមុខចៀរផ្កាប់

<u>ឃ) ចំឡើយទាំង៣ខាងលើត្រូវទាំងអស់</u>

**៥២. តើហេតុអ្វីពេលគូសចែកមុខចៀរចំនួន២ នៅលើផ្ទាំងចៀរតែ១ ត្រូវអោយមានគំលាតពីមុខចៀរមួយទៅមុខចៀរមួយទៀតយ៉ាងតិចបំផុត គឺ ៣០ស.ម?**

<u>ក) ដើម្បីចៀសវាងការត្រួតគ្នាលើតំបន់ទាញយកជ័ររបស់មុខចៀរទាំង២ កាត់បន្ថយទិន្នផលជ័រ</u>

ខ) ដើម្បីងាយស្រួលត្រួតពិនិត្យបច្ចេកទេសចៀរសំរាប់មុខចៀរនិមួយៗ

គ) ចៀសវាងការឆ្លងជម្ងឺពីផ្ទាំងចៀរ

ឃ) សន្សំសំចៃសម្ភារៈបំពាក់សំរាប់ដើមកៅស៊ូ

**៥៣. តើហេតុអ្វីមុខចៀរផ្កាត្រូវមានចំណោតធាក់ចុះ ពីខាងឆ្វេងទៅស្តាំ ប្រៀបធៀបនឹងអ័ក្សផ្តេក?**

ក) ពីព្រោះគាត់បានសរសៃជ័រច្រើនបំផុត

ខ) ពីព្រោះជាតម្រូវការនៃកាយវិការចៀរជ័រ

គ) ពីព្រោះតាមទម្លាប់ដែលមានតាំងពីយូរមកហើយ

ឃ) ពីព្រោះនឹងសម្រួលដល់ការទាញយកជ័រដែលមានក្នុងដើមកៅស៊ូ

**៥៤. តើបច្ចុប្បន្នដើមកៅស៊ូដែលទើបបើកមុខចៀរជ័រ មានកំពស់បើកមុខប៉ុន្មានស.មឃ្លាតពីដី?**

ក) ១០០ស.ម

ខ) ១២០ស.ម

គ) ១៣០ស.ម

ឃ) ១៥០ស.ម

**៥៥. តើបច្ចេកទេសឆូតចង្អូរបង្ហូរទឹកជ័រនៅព្រំខាងមុខ មានដូចម្តេចខ្លះ?**

ក) ឆូតចង្អូរបង្ហូរទឹកជ័រនៅព្រំខាងមុខ ចាប់ពីចំណុចបើកមុខដល់កន្លែងបញ្ចុះស្លាបព្រា មានជម្រៅដល់ផ្នែកសាច់ម៉ត់ នៃស្រទាប់កណ្តាល "ខាងលើធំបង្រួមចុះមកខាងក្រោមតូច" ទិសតម្រង់ចុះត្រង់នឹងផ្ទៃដី
ខ) ឆូតចង្អូរបង្ហូរទឹកជ័រនៅព្រំខាងមុខ និង បន្ទាត់ព្រំខាងក្រោយអោយច្បាស់ឡើងវិញ កែតម្រូវចង្អូរអោយត្រង់ ស្របនឹងបន្ទាត់បណ្តោយតាមតួដើមកៅស៊ូ
គ) កែតម្រូវកន្លែងបញ្ចុះស្លាបព្រាជាមួយនឹងចង្អូរនៅព្រំខាងមុខឡើងវិញ ក្រោយចៀរជ័របានមួយរយៈ
ឃ) ចំឡើយ ក និង ចំឡើយ គ ត្រូវទាំងពីរ

## លក្ខណៈជីវសាស្ត្ររបស់ទឹកជ័រកៅស៊ូ (០២ សំណួរ)

**៥៦. ចូរអោយដឹងថាសរសៃជ័រក្នុងសំបកដើមកៅស៊ូ មានច្រើនបំផុតនៅ៖**

ក) ស្រទាប់ខាងក្រៅ

ខ) ស្រទាប់កណ្តាល

គ) ស្រទាប់ខាងក្នុង

zឃ) ស្រទាប់ឈើខ្ចី (កាំប៊ីយូម)

៥៧. ចូរបញ្ជាក់អំពីមូលហេតុធ្វើអោយជ័រក្នុងចានឆាប់កក ប៉ះពាល់ដល់ការប្រមូលផល កាត់បន្ថយគុណភាពជ័រទឹក៖

ក) ដោយសារកំហុសបច្ចេកទេសចៀរ

ខ) ដោយសារការផ្លាស់ប្តូរប្រព័ន្ធចៀរ

គ) ដោយសារការប្រើប្រាស់ថ្នាំរំញោច

ឃ) ដោយសារក្នុងទឹកជ័រមានពពួកមីក្រូសរពាង្គកាយ វាប្រើប្រាស់សារធាតុប្រូតេអ៊ីន (protein) កាបូហ៊ីដ្រាស៍ (carbohydrase) ស្ករ និងសារធាតុសរីរាង្គទាំងឡាយដែលមានក្នុងទឹកជ័រ ដើម្បី បង្កើតនូវជាតិអាស៊ីតដែលងាយសាយភាយ បង្កអោយកកទឹកជ័រ

**គម្រូវការបច្ចេកទេស (៤៣ សំណួរ)**

**ជំរៅ (៦ សំណួរ)**

**៥៨. តើទំហំ និងលទ្ធភាពដុះថ្មីឡើងវិញរបស់សំបកចៀរអាស្រ័យទៅតាមកត្តាទាំងឡាយណា?**

ក) លក្ខណៈពិសេសរបស់ពូជកៅស៊ូ និងលក្ខខ័ណ្ឌដាក់ជីថែទាំចំការ

ខ) លក្ខណៈអាកាសធាតុ ដង់ស៊ីតេដាំ និងស្ថានភាពបំផ្លាញរបស់ជម្ងឺ

គ) ប្រព័ន្ធចៀរ និង កំរិតចៀរ

<u>ឃ) ចំឡើយទាំង៣ខាងលើត្រូវទាំងអស់</u>

**៥៩. តម្រូវការចំពោះកម្រាស់សំបកជាអប្បរិមាណ ដើម្បីបើកមុខចៀរជ័រមានប្រសិទ្ធិភាពគឺ៖**

ក) ៥ម.ម

<u>ខ) ៦ម.ម</u>

គ) ៧ម.ម

ឃ) ៨ម.ម

**៦០. តើហេតុអ្វីការចៀររាក់ប្រមូលផលជ័រមិនបានច្រើន?**

ក) ពីព្រោះមិនប្រមូលបានអស់ទឹកជ័រនៅតំបន់ទាញយកជ័រ

ខ) <u>ពីព្រោះការចៀររាក់មិនអាចកាត់បានសរសៃជ័រច្រើននៅតំបន់ទាញយកជ័រ ដែលប្រមូលផ្តុំនៅតំបន់កៀកជិតស្រទាប់ឈើខ្ចី (១,០ - ១,៣ម.ម)</u>

គ) ដោយសារការចៀររាក់ពុំមានសម្ពាធគ្រប់គ្រាន់ដើម្បីធ្វើអោយទឹកជ័រហូរចេញ

ឃ) ចំឡើយទាំង៣ខាងលើត្រូវទាំងអស់

**៦១. តើការចៀរប៉ះសាច់ឈើគឺចៀររបួស លក្ខណៈស្នាមរបួសដូចម្តេចហៅថាចៀររបួសធ្ងន់?**

<u>ក) ប្រវែងស្នាមរបួស វែងជាង៥ម.ម ទទឹងធំជាង៣ម.ម</u>

ខ) ប្រវែងស្នាមរបួស វែងជាង ៥ម.ម ទទឹងតូចជាង ៣ម.ម

គ) ប្រវែងស្នាមរបួស ខ្លីជាង ៥ម.ម ទទឹងធំជាង ៣ម.ម

ឃ) ប្រវែងស្នាមរបួស ខ្លីជាង ៥ម.ម ទទឹងតូចជាង ៣ម.ម

**៦២. តើជម្រៅចៀរត្រូវបានកំណត់អោយឃ្លាតពីឈើខ្ចីប៉ុន្មាន ម.ម?**

ក) ចាប់ពី ១,១ម.ម ដល់១,៣ម.ម

ខ) ចាប់ពី ១,១ម.ម ដល់១,៥ម.ម

<u>គ) ចាប់ពី ១,០ម.ម ដល់១,៣ម.ម</u>

ឃ) ចាប់ពី ១,០ម.ម ដល់ ១,៥ម.ម

**៦៣. តើហេតុអ្វីការចៀរជ័រត្រូវចៀរដល់ជម្រៅកំណត់ ឃ្លាតពីឈើខ្លឹមពី ១,០ម.ម ទៅ ១,៣ម.ម?**

ក) ពីព្រោះនឹងរក្សាបានស្រទាប់លីបែ (Libe) ដើម្បីបញ្ជូននូវសារធាតុអាណាបូលីត៍ (Anabolite) ដែលសំយោគបានពីស្លឹក ចុះមកក្រោមសំរាប់បង្កើតទឹកជ័រឡើងវិញ
ខ) ពីព្រោះនឹងកាត់បានសរសៃជ័រយ៉ាងច្រើនបំផុត
គ) មិនបង្កអោយមានកំពឹកកំពកលើផ្ទាំងចៀរ ដើម្បីអាចធ្វើការចៀរលើផ្ទៃកសំបកដុះថ្មីឡើងវិញ
<u>ឃ) ចំឡើយខាងលើត្រូវទាំងអស់</u>

**ការចំណាយអាចម៍ពន្លាកចៀរ ( ៧ សំណួរ )**

**៦៤. តើការចំណាយអាចម៍ពន្លាកត្រូវបានកំណត់ សម្រាប់ការចៀរតាមសង្វាក់ចៀរ d3 គឺមាន កម្រាស់ប៉ុន្មាន ម.ម ក្នុងមួយពន្លាក?**

ក) ចំពោះមុខចៀរផ្ចារ ការចំណាយអាចម៍ពន្លាកត្រូវបានកំណត់ពី ១,១ម.ម ដល់ ១,៥ម.ម/ពន្លាក
ខ)- ចំពោះមុខចៀរផ្អាប់ដោយមានការត្រួតពិនិត្យ ការចំណាយអាចម៍ពន្លាកត្រូវបានកំណត់មិនអោយលើស ពី ២ម.ម/ពន្លាក
គ) ចំពោះមុខចៀរផ្អាប់ក្រៅពីការត្រួតពិនិត្យ ការចំណាយអាចម៍ពន្លាកត្រូវបានកំណត់ពី ៣ម.ម ក្នុងមួយពន្លាក
<u>ឃ) ចំឡើយទាំង៣ខាងលើត្រូវទាំងអស់</u>

**៦៥. តើការចំណាយអាចម៍ពន្លាកត្រូវបានកំណត់ជាអតិបរិមាណ សម្រាប់ប្រព័ន្ធចៀរ S/2 d3 6d/7 គឺប៉ុន្មានស.ម ក្នុង១ឆ្នាំ?**

ក) ១៥ស.ម
ខ) ១៦ស.ម
គ) ១៧ស.ម
<u>ឃ) ១៨ស.ម</u>

**៦៦. តើការចំណាយអាចម៍ពន្លាកជាអតិបរិមាណត្រូវបានកំណត់ ចំពោះប្រព័ន្ធចៀរ S/2 d4 6d/7 គឺប៉ុន្មាន ស.ម ក្នុង១ឆ្នាំ?**

<u>ក) ១៥ស.ម</u>
ខ) ១៦ស.ម
គ) ១៧ស.ម
ឃ) ១៨ស.ម

**៦៧. តើហេតុអ្វីមិនអនុញ្ញាតអោយចៀរអាចម៍ពន្លាកក្រាស់?**

ក) ការចៀរអាចម៍ពន្លាកក្រាស់នឹងបង្កអោយកកទឹកជ័រនៅលើមុខចៀរ
ខ) ការចៀរអាចម៍ពន្លាកក្រាស់នឹងបង្កអោយដើមកៅស៊ូអន់ខ្សោយ
<u>គ) ការចៀរក្រាស់នឹងប្រើប្រាស់អស់សំបកចៀរច្រើន ប៉ុន្តែមិនបង្កើនទិន្នផលជ័រ បង្កផលវិបាក គឺមិនអាចអនុវត្តតាមគម្រោងការគូសចែកសំបកចៀរ</u>
ឃ) ចៀរអាចម៍ពន្លាកក្រាស់ងាយបង្កអោយដើមកៅស៊ូស្ងួតមុខចៀរ

**៦៨. ការចំណាយអាចម៍ពន្លាកជាអតិបរិមាណ ត្រូវបានអនុញ្ញាតិសម្រាប់ការចៀរបើកមុខ គឺ៖**

ក) ២ម.ម
<u>ខ) ២ស.ម</u>
គ) ពី ១,១ស.ម ទៅ ១,៥ស.ម
ឃ) ក្រោម ៣ស.ម

**៦៩. តើតាមបទដ្ឋានបច្ចេកទេសបំពេញបន្ថែមឆ្នាំ២០១៧ ការចំណាយអាចម៍ពន្លាក និងការចំណាយ សំបកចៀរ ត្រូវបានកំណត់ចំពោះសង្វាក់ចៀរ d5 និង d6 ដូចម្តេច?**

ក) ចំណាយអាចម៍ពន្លាក ១,១ - ១,៥ម.ម/ពន្លាក។ ចំណាយសំបកជាអតិបរិមាណ ១០ស.ម/ឆ្នាំ សម្រាប់សង្វាក់ចៀរ d5 និង ០៨ស.ម/ឆ្នាំ សម្រាប់សង្វាក់ចៀរ d6
<u>ខ) ចំណាយអាចម៍ពន្លាក ១,៥ - ២,០ម.ម/ពន្លាក។ ចំណាយសំបកជាអតិបរិមាណ ១៨ស.ម/ឆ្នាំ សម្រាប់សង្វាក់ចៀរ d5 និង ១២ស.ម/ឆ្នាំ សម្រាប់សង្វាក់ចៀរ d6</u>
គ) ចំណាយអាចម៍ពន្លាក ១,១ - ១,៦ម.ម/ពន្លាក។ ចំណាយសំបកជាអតិបរិមាណ ១១ស.ម/ឆ្នាំ សម្រាប់សង្វាក់ចៀរ d5 និង ០៩ស.ម/ឆ្នាំ សម្រាប់សង្វាក់ចៀរ d6
ឃ) ចំណាយអាចម៍ពន្លាក ១,២ - ២,០ម.ម/ពន្លាក។ ចំណាយសំបកជាអតិបរិមាណ ១២ស.ម/ឆ្នាំ សម្រាប់សង្វាក់ចៀរ d5 និង ១០ស.ម/ឆ្នាំ សម្រាប់សង្វាក់ចៀរ d6

**៧០. តើមូលហេតុអ្វីគេត្រូវគូសលំនាំកំណត់ការចំណាយសំបកចៀរសម្រាប់ត្រីមាស និងសម្រាប់ខែ នីមួយៗ នៅលើសំបកដើមកៅស៊ូចៀរជ័រ?**

<u>ក) ដើម្បីធានាដល់តម្រូវការនៃការបែងចែកសំបកចៀរ សំរាប់រយៈពេលវែង និង ជួយអោយកម្មករចៀរជ័រ អាចរក្សាបានកំរិតចំណោតរបស់មុខចៀរត្រូវតាមកំណត់</u>
ខ) ដើម្បីកម្មករចៀរជ័រអាចមើលឃើញចង្អូរមុខចៀររបស់ខ្លួន
គ) ដើម្បីងាយស្រួលត្រួតពិនិត្យការចំណាយអាចម៍ពន្លាកចៀរ
ឃ) ដើម្បីទប់ស្កាត់ការរំលងដើមចៀររបស់កម្មករចៀរជ័រ

## លក្ខណៈបច្ចេកទេសសម្រាប់ចន្លោះមុខចៀរ (២ សំណួរ)

**៧១. លក្ខណៈបច្ចេកទេសសម្រាប់ចន្លោះមុខចៀរ៖**

ក) ត្រឹមត្រូវតាមប្លង់គូសចែកមុខចៀរ នៅពេលបើកមុខចៀរ

<u>ខ) ត្រូវតាមចំណោតកំណត់ ចន្លោះមុខចៀរមានរាងផតស្នូកបាយជ្រូក កែងនឹងព្រំខាងមុខ និង ព្រំខាងក្រោយ មិនត្រូវលោតរលក ខុសលំនាំមុខចៀរ និង មិនត្រូវចៀរហួសព្រំដែន</u>

គ) ត្រូវតាមជំរៅកំណត់ មានរាងផតស្នូកបាយជ្រូក កែង មិនលោតរលក មិនខុសលំនាំមុខចៀរ

ឃ) ត្រូវតាមការចំណាយអាចម៍ពន្លាកដែលបានកំណត់ ធានាចំណោត មិនត្រូវខុសលំនាំមុខចៀរ

**៧២. តើហេតុអ្វីត្រូវចៀរអោយកែងនឹងព្រំខាងមុខ និង ព្រំខាងក្រោយ**

ក) ដើម្បីចៀរសរាងកុំអោយដើមកៅស៊ូស្ងួតមុខចៀរ

<u>ខ) ចៀរអោយកែងនឹងព្រំខាងមុខ និង ព្រំខាងក្រោយ ដើម្បីកាត់អោយអស់សរសៃរជ័រនៅតំបន់ទាញយក ជ័ររបស់ដើមកៅស៊ូ និងប្រមូលជ័របានច្រើន</u>

គ) ចៀរអោយកែងនឹងព្រំខាងមុខ និង ព្រំខាងក្រោយ ដើម្បីរក្សាអោយផ្ទាំងចៀរស្អាត

ឃ) ចំឡើយទាំង៣ខាងលើខុសទាំងអស់

## ការងារផ្សេងៗ (៤ សំណួរ)

**៧៣. តើដើមកៅស៊ូជ្រុះស្លឹកនៅរដូវរងាជារៀងរាល់ឆ្នាំ គេត្រូវឈប់សំរាកចៀរនៅពេលណា?**

ក) ឈប់សំរាកចៀរជ័រនៅពេលដើមកៅស៊ូចាប់ផ្តើមលាស់ស្លឹកថ្មី ដំណុះស្លឹកមានរាងដូចជើងក្អែក

ខ) ឈប់សំរាកទូទាំងចំការនៅពេលមាន ៣០% ដើមកៅស៊ូលាស់ស្លឹកថ្មី ដំណាក់កាលដំណុះស្លឹកមានរាងដូចជើងក្អែក

គ) ចំការណាជ្រុះស្លឹកមុន ត្រូវឈប់សម្រាកចៀរមុន

<u>ឃ) ចំឡើយទាំង៣ខាងលើត្រូវទាំងអស់</u>

**៧៤. តើកម្មករចៀរជ័រត្រូវធ្វើអ្វី មុនចូលរដូវឈប់សំរាកចៀរជ័រជារៀងរាល់ឆ្នាំ?**

ក) ធ្វើការចៀរជ័រយ៉ាងសកម្ម ដើម្បីយកបរិមាណជ័រសំរាប់ផែនការនឹងទទួលនៅឆ្នាំក្រោយ

<u>ខ) សំអាតពានចៀររបស់ខ្លួន ប្រមែប្រមូលអោយអស់ជ័រផ្សេងៗ ជ័រដី។ ប្រមូលសំភារៈ លួសកងទ្រចានស្លាបព្រា ចានត្រងជ័រ សំអាត ទុកដាក់សំភារៈនៅកន្លែងដែលអាចថែរក្សាបានល្អ។ បោសសំអាតប្រមូលស្លឹកឈើ និងធ្វើផ្លូវការពារភ្លើងឆេះចំការ</u>

គ) ប្រមែប្រមូលជ័រផ្សេងៗ ជ័រដី ការពារភ្លើងឆេះចំការនៅរដូវប្រាំង

ឃ) ប្រគល់ពានចៀរអោយទៅកម្លាំងការពារសន្តិសុខដើម្បីឈប់សំរាកចៀរ

**៧៥. តើពេលធ្វើការចៀរប្រមែប្រមូលជ័រនៅលើមែកដែលខ្ពស់នៅខាងលើ គេត្រូវធ្វើដូចម្តេចដើម្បីតម្រងទឹកជ័រអោយហូរចូលក្នុងចាន?**

<u>ក) តម្រងទឹកជ័រពីស្លាបព្រា អោយហូរចូលក្នុងចានត្រងជ័រដោយប្រើខ្សែតម្រង</u>
ខ) តម្រងជ័រដោយឆូតចង្អូរមួយមានប្រវែងពីមុខចៀរ ចុះមកស្លាបព្រាដើម្បីបង្ហូរទឹកជ័រចូលក្នុងចាន
គ) ចំឡើយ ក និង ចំឡើយ ខ ខុសទាំងពីរ
ឃ) ចំឡើយ ក និង ចំឡើយ ខ ត្រូវទាំងពីរ

**៧៦. តើតាមបទដ្ឋានបំពេញបន្ថែមឆ្នាំ២០១៧ ការលាបខ្លាញ់ vaselin ដើម្បីបិទមុខចៀរ មុនពេលឈប់សម្រាកត្រូវបានកំណត់ ដូចម្តេច?**

ក) អនុវត្តចំពោះតំបន់ដែលរងផលប៉ះពាល់អវិជ្ជមានពីលក្ខណៈអាកាសធាតុ រួមមានតំបន់ខាងជើងនៃភាគកណ្តាល តំបន់ព្រៃភ្នំនៃភាគខាងជើងប្រទេសវៀតណាម និង ប្រទេសឡាវ ប្រទេសកម្ពុជា...
ខ) លាបខ្លាញ់ (Vaselin) ទៅលើផ្ទាំងចៀរសំបកដុះថ្មីឡើងវិញ ដែលជាប់គ្នានឹងមុខចៀរ និងលាបលើផ្ទៃទទឹងទំហំ ០៤ស.ម (សម្រាប់សង្វាក់ចៀរ d4, d5) និង ០៥ស.ម (សម្រាប់សង្វាក់ ចៀរ d3) និងមានប្រវែងពីព្រំខាងមុខដល់ព្រំខាងក្រោយ ដើម្បីការពារផ្ទាំងចៀររបស់ដើមចៀរទាំងអស់ក្នុងចំការអាជីវកម្ម ចំពោះផលប៉ះពាល់អវិជ្ជមានពីលក្ខណៈអាកាសធាតុ ដូចជា ស្ថានភាពត្រជាក់ខ្លាំង ឬក្តៅពេក...
គ) ធ្វើការលាបនៅពេលៈ មុនចូលរដូវឈប់សម្រាកចៀរ ក្រោយពេលប្រមែប្រមូលអស់ជ័រផ្សេងៗ ជ័រដីនឹងក្រោយសំអាតកានចៀររួច
<u>ឃ) ចំឡើយ ក ខ និង គ ខាងលើ ត្រូវទាំងអស់</u>

**ពេលម៉ោងចៀរជ័រ - សារជ័រ (៣ សំណួរ)**

**៧៧. តើពេលម៉ោងសម្រាប់ការចៀរជ័រ ក្នុងថ្ងៃធ្វើការចៀរ ត្រូវបានកំណត់ ដូចម្តេច?**

ក) <u>ចាប់ផ្តើមធ្វើការចៀរនៅពេលមើលឃើញច្បាស់ចង្អូរមុខចៀរ។ ក្នុងរដូវភ្លៀងត្រូវរងចាំអោយផ្ទាំងចៀរស្ងួតល្អទើបអាចធ្វើការចៀរបាន។ ករណីរងចាំដល់វេលាម៉ោង ១១:00 - ១២:00ថ្ងៃត្រង់ ផ្ទាំងចៀរនៅតែសើម ត្រូវឈប់សម្រាកចៀរនៅថ្ងៃនោះ។</u>
ខ) ធ្វើការចៀរដោយឆ្លៀតពេលតាំងពីព្រឹកព្រលឹម ដែលព្រះអាទិត្យមិនទាន់រះ។ ថ្ងៃណាមានភ្លៀងធ្លាក់ត្រូវផ្អាកការចៀរជ័រ
គ) រងចាំដល់មេឃភ្លឺច្បាស់ទើបចាប់ផ្តើមចៀរ ដើម្បីចៀសវាងកុំអោយមានកំហុសបច្ចេកទេស
ឃ) ចាប់ផ្តើមចៀរនៅពេលណាក៏បាន ដែលយល់ឃើញថាងាយស្រួល

**៧៨. តើក្រោយពេលចៀរជ័រក្នុងកានចៀររបស់ខ្លួនរួចរាល់ហើយនោះ ពេលវេលាណាដែលកម្មករ ចៀរជ័រចាប់ផ្តើមសារជ័រ?**

<u>ក) នៅពេលមានសញ្ញាបញ្ជាអោយសារជ័រពីប្រធានក្រុម ប្រធានផ្នែក</u>
ខ) ពេលណាក៏បាន អាស្រ័យទៅតាមសុខភាពរបស់កម្មករចៀរ
គ) ពេលថ្ងៃត្រង់
ឃ) ពេលមេឃរកធ្លាក់ភ្លៀង

**៧៩. តើដើម្បីធានាគុណភាពជ័រនៅពេលប្រមូល និងទទួលជ័រ ត្រូវធ្វើដូចម្តេច?**

ក) ពេលចាក់ជ័រទឹកពីប៉ោតសារជ័រចូលក្នុងប៉ោតដាក់ជ័រ ត្រូវប្រើកន្ត្រងព្រោះទឹកជ័រមានរន្ធទំហំ ៥ម.ម

ខ) ពេលចាក់ជ័រទឹកពីប៉ោតដាក់ជ័រ ចូលក្នុងស៊ីទែនដាក់លើរថយន្តដឹកជ័រ ត្រូវប្រើសំណាញ់ព្រោះទឹកជ័រមានរន្ធទំហំ ៣ម.ម

គ) ពេលចាក់ជ័រទឹកពីប៉ោតសារជ័រចូលក្នុងប៉ោតដាក់ជ័រ មិនត្រូវប្រើប្រាស់កន្ត្រងព្រោះទឹកជ័រ

<u>ឃ) មានតែចំឡើយ ក និង ចំឡើយ ខ គឺត្រូវ</u>

**ការធ្វើរំញោច(៨ សំណួរ)**

**៨០. តើលក្ខណៈសម្បត្តិសរបស់ដើមកៅស៊ូដាក់ឱ្យធ្វើរំញោច មានដូចម្តេច?**

ក) ដើមលូតលាស់ធម្មតា

ខ) បច្ចេកទេសចៀរល្អ

គ) មិនត្រូវធ្វើរំញោចចំពោះដើមបាក់ចុងកណ្តាល ដើមមានជម្ងឺកំរិតធ្ងន់ ដើមមានសញ្ញាស្ងួតផ្ទាំងចៀរ ឬ ទំហំដើមតូចពេក

<u>ឃ) ចំលើយទាំង៣ខាងលើត្រូវទាំងអស់</u>

**៨១. វិធានការធ្វើរំញោចទាំងឡាយ បច្ចុប្បន្នកំពុងអនុវត្ត ដើម្បីបង្កើនទិន្នផលជ័រ គឺ៖**

ក) ប្រើសមាសធាតុគីមីដែលមានធាតុសកម្ម អេតេផុន (Ethephon) លាបទៅលើដើមកៅស៊ូ

ខ) អោយដើមកៅស៊ូស្រូបយកឧស្ម័នអេទីឡែន (Ethylen) ដោយផ្ទាល់

គ) ធ្វើរំញោចដោយកាំរស្មីឡាស៊ែរ (Laser)

<u>ឃ) មានតែចំឡើយ ក និង ចំឡើយ ខ គឺត្រូវ</u>

**៨២. តើការរក្សាទុកថ្នាំរំញោច (Ethephon) មានតម្រូវការដូចម្តេច?**

ក) ចៀសវាងទុកដាក់នៅកន្លែងសើម ខ្វះពន្លឺ

ខ) រក្សាទុកនៅកន្លែងដាច់ដោយឡែក សីតុណ្ហភាពពី ២០ - ៣០0C គ្របជិត និង ធានាសុវត្ថិភាព

គ) ទុកដាក់នៅកន្លែងផុតពីការប៉ះពាល់របស់កូនក្មេង

<u>ឃ) ត្រូវរក្សាទុកថ្នាំរំញោចនៅក្នុងម្លប់ កុំអោយប៉ះនឹងពន្លឺព្រះអាទិត្យដោយផ្ទាល់ ការប្រើប្រាស់ត្រូវគោរពតាមកាលកំណត់ដែលមានបញ្ជាក់លើសំបកវេចខ្ចប់</u>

**៨៣. តើតម្រូវការអំពីសុវត្ថិភាពការងារនៅពេលប្រើប្រាស់ថ្នាំរំញោច(Ethephon) មានដូចម្តេច?**

ក) ពេលលាបថ្នាំរំញោចលើមុខចៀរដែលខ្ពស់នៅខាងលើ ត្រូវពាក់វ៉ែនតាការពារ

ខ) ចៀសវាងកុំអោយថ្នាំរំញោចប៉ះពាល់ដល់ស្បែក ខ្ទាតចូលភ្នែក។ ករណីថ្នាំរំញោចប៉ះពាល់ដល់ស្បែក ត្រូវលាងនឹងសាប៊ូនិងទឹកក្តៅអ៊ុនៗជាបន្ទាន់។ ប្រសិនបើថ្នាំរំញោចខ្ទាតចូលភ្នែក ត្រូវលាងនឹងទឹកស្អាតជាបន្ទាន់ និងលាងអោយបានច្រើនដង

គ) ក្រោយពេលប្រើប្រាស់រួច ត្រូវកំទេចចោលសំបកដាក់ថ្នាំរំញោច ពុំត្រូវប្រើប្រាស់ឡើងវិញដើម្បីគោលបំណងផ្សេងទៀត

<u>ឃ) ចំឡើយទាំង៣ខាងលើ គឺត្រូវទាំងអស់</u>

**៨៤. តើថ្នាំរំញោចអេតេផុន(Ethephon) មានប៉ះពាល់អ្វីដល់គុណភាពឈើកៅស៊ូនៅថ្ងៃក្រោយ ដែរឬទេ?**

ក) មានប៉ះពាល់ដល់គុណភាពឈើ

ខ) មានប៉ះពាល់ដល់គុណភាពឈើ ក្នុងករណីបើប្រើប្រាស់ថ្នាំរំញោចជាបន្តបន្ទាប់ និងប្រើប្រាស់ក្នុងរយៈពេលយូរ

គ) មិនប៉ះពាល់អ្វីដល់គុណភាពឈើកៅស៊ូ

ឃ) កំពុងសិក្សាស្រាវជ្រាវ

**៨៥. តើមិនត្រូវលាបថ្នាំរំញោចអេតេផុន (Ethephon) នៅពេលណា?**

ក) ពេលមេឃរគផ្លាក់ភ្លៀង ឬ ផ្ទាំងចៀរនៅសើម

ខ) ពេលមានកំដៅថ្ងៃខ្លាំង

គ) ក្នុងរដូវដើមកៅស៊ូលាស់ស្លឹកថ្មី ឬ ពេលចំការកំពុងមានជម្ងឺ

ឃ) ចំឡើយទាំង៣ខាងលើត្រូវទាំងអស់

**៨៦. ផលប្រយោជន៍ពីការប្រើប្រាស់ថ្នាំរំញោច ដើម្បីបង្កើនទិន្នផលជ័រ បានបង្ហាញច្បាស់តាមរយៈ៖**

ក) បង្កើនផលិតភាពពលកម្មក្នុងការចៀរជ័រ

ខ) កាត់បន្ថយអត្រាកើតជម្ងឺស្ងួតមុខចៀរ

គ) សន្សំសំចៃបរិមាណជី

ឃ) អូសបន្លាយរយៈពេលហូរទឹកជ័រ

**៨៧. តើចំការកៅស៊ូមិនត្រូវអនុញ្ញាតអោយប្រើប្រាស់ថ្នាំរំញោច មានលក្ខណៈដូចម្តេច?**

ក) មិនបំពាក់របាំងការពារទឹកភ្លៀង

ខ) កំពុងចៀរជ័រតាមសង្វាក់ចៀរ d2

គ) កំពុងចៀរផ្តាប់ដោយមានការត្រួតពិនិត្យ

ឃ) ផ្អាកការចៀរជ័រអស់មួយរយៈពេលយូរ

## ការថែទាំ និងការគ្រប់គ្រងចំការកៅស៊ូអាជីវកម្ម (៥ សំណួរ)

**៨៨. តើហេតុអ្វីមិនត្រូវភ្ជួរដីតាមចន្លោះជួរកៅស៊ូក្នុងចំការអាជីវកម្ម?**

ក) ពីព្រោះនឹងធ្វើអោយដាច់ឫសស្រូបយកសារធាតុចិញ្ចឹមរបស់ដើមកៅស៊ូ និងបង្កអោយហូរច្រោះដី

ខ) ពីព្រោះភ្ជួរនឹងប៉ះពាល់ដល់លទ្ធភាពផ្តល់ជ័ររបស់ដើមកៅស៊ូ

គ) ភ្ជួរដីតាមចន្លោះជួរកៅស៊ូនឹងបង្កអោយដើមកៅស៊ូស្ងួតផ្ទាំងចៀរ

ឃ) ភ្ជួរដីតាមចន្លោះជួរកៅស៊ូគ្មានផលចំណេញលើផ្នែកសេដ្ឋកិច្ច

**៨៩.តើវិធានការសំអាតស្មៅតាមចន្លោះជួរ សំរាប់ចំការកៅស៊ូអាជីវកម្ម ត្រូវអនុវត្តដូចម្តេច?**

ក) សំអាតអោយអស់ស្មៅដើម្បីបំបាត់លក្ខណៈបង្កការកកើតជម្ងឺ
ខ) ភ្ជួរត្រឡប់ដី ដើម្បីសម្លាប់អស់ស្មៅចង្រៃ
គ) កាប់ស្មៅតាមចន្លោះជួរជាប្រចាំ ដោយរក្សាទុកគម្របស្មៅមានកំពស់ពី ១០ ទៅ ១៥ស.ម ដើម្បីទប់ស្កាត់ការហូរច្រោះ
ឃ) សំអាតស្មៅដោយគួបផ្សំហាត្ថកម្ម ជាមួយនឹង គ្រឿងយន្ត

**៩០. តើក្នុងរដូវដើមកៅស៊ូលាស់ស្លឹកថ្មីជារៀងរាល់ឆ្នាំ កម្មករនឹងធ្វើការងារមួយណា ក្នុងចំណោម ការងារមួយចំនួនមានដូចខាងក្រោម?**

ក) លាបថ្នាំការពារជម្ងឺស្ងួតក្រៀមដោយសារកំដៅថ្ងៃ
ខ) ដាក់ជីអោយចំការ
គ) ការពារភ្លើងឆេះចំការ
ឃ) លាបថ្នាំរំញោច

**៩១. តើករណីភ្លើងឆេះចំការ ប៉ុន្តែអាចស្តារឡើងវិញបាន គេត្រូវអនុវត្ត ដូចម្តេច៖**

ក) លាបម្សៅស្ពាន់ធ័រស្រុបទឹក (Sulox, Kumulus) កំហាប់ 0,៣% លើផ្នែកសំបករបួស
ខ) កោសសំអាតស្រទាប់សំបករបួស
គ) ប្រើដែកស្រួចចាក់ស្ទង់មើលនៅខាងក្រោមមុខចៀរ ដើម្បីកំណត់បានតំបន់សំបកស្ងួតក្រៀម ទើបធ្វើការចៀរដាច់ដោយឡែក
ឃ) លាបសូលុយស្យុងកំបោរ ៥% ទៅលើផ្នែកសំបកដែលរងផលប៉ះពាល់

**៩២. តើចំពោះចំការកៅស៊ូអាជីវកម្ម មុនកាប់ចោលដើមកៅស៊ូចាស់ៗ និងដាំថ្មីឡើងវិញគេត្រូវធ្វើដូចម្តេចដើម្បីសំរេចបាននូវប្រសិទ្ធិភាពខ្ពស់?**

ក) មានផែនការចៀរប្រមែប្រមូលជ័រក្នុងរយៈពេល១ឆ្នាំ
ខ) មានផែនការចៀរប្រមែប្រមូលជ័រក្នុងរយៈពេលតិចបំផុត ២ឆ្នាំ
គ) មានផែនការចៀរប្រែប្រមូលជ័រក្នុងរយៈពេល ១ឆ្នាំ ៦ខែ
ឃ) ដល់អាយុចៀរជ័រឆ្នាំទី២០ នឹងកាប់ចោលដើមកៅស៊ូចាស់ៗតែម្តង ដោយមិនចាំបាច់ចៀរប្រមែប្រមូលជ័រ

## សញ្ញាសន្មត (៦ សំណួរ)

**៩៣. សញ្ញាសន្មតកំហុសបច្ចេកទេសចៀររបួសខ្លាំងលើជើមកៅស៊ូគឺ៖**

ក) II
ខ) W
គ) A
ឃ) V

**៩៤. សញ្ញាសន្មតកំហុសបច្ចេកទេសធ្វើអនាម័យខ្សោយគឺ៖**

ក) Δ
ខ) ∇
គ) II
ឃ) W

**៩៥. សញ្ញាសន្មតកំហុសបច្ចេកទេសចៀររាក់ខ្លាំងគឺ៖**

ក) Δ
ខ) V
គ) ∀
ឃ) Λ

**៩៦. សញ្ញាសន្មតកំហុសបច្ចេកទេសចៀរអាចម៍ពន្លាកក្រាស់ខ្លាំងគឺ៖**

ក) Δ
ខ) ~~X~~
គ) A
ឃ) V

៩៧. សញ្ញា ∇ ជាការសន្មតចំពោះកំហុសបច្ចេកទេស៖
ក) អនាម័យខ្សោយ
ខ) ប្រមែប្រមូលជ័រខ្សោយ
គ) ចៀរអាចម៍ពន្លាកក្រាស់ខ្លាំង
ឃ) ចៀររាក់ខ្លាំង

**៩៨. សញ្ញាសន្ទតកំហុសបច្ចេកទេសមុខចៀរលោតរលកគឺ៖**

ក) Δ
ខ) ∇
គ) ll
<u>ឃ) W</u>

**ដើមស្ងួតមុខចៀរ (២ សំណួរ)**

**៩៩. តើពេលរកឃើញដើមកៅស៊ូស្ងួតមុខចៀរ កម្មករចៀរជ័រនឹងធ្វើដូចម្តេច?**

ក) ត្រូវផ្អាកការចៀរ និង ពិនិត្យនៅតំបន់ស្ងួតជ័រភ្លាម ដើម្បីអនុវត្តការចៀរដាច់ដោយឡែក និង ផ្លាស់ប្តូរផ្ទាំងចៀរ
ខ) លាបថ្នាំរំញោចដើម្បីធ្វើការចៀរបន្ត
គ) ដាក់ជីបន្ថែមសម្រាប់ដើមស្ងួតមុខចៀរ
<u>ឃ) រាយការណ៍ដល់ប្រធានក្រុម បុគ្គលិកបច្ចេកទេស ដើម្បីមានដំណោះស្រាយ</u>

**១០០. តើសញ្ញាពិសេសនៃបាតុភូតស្ងួតមុខចៀរមានដូចម្តេច?**

ក) ដើមងាប់បញ្ច្រាស់ពីក្រោមឡើងលើ ជ្រុះស្លឹក ស្ងួតមុខចៀរ មិនផ្តល់ជ័រ
ខ) ផ្ទាំងចៀរស្ងួតក្រៀមតែម្ខាង ករណីជម្ងឺរាតត្បាតដល់កំរិតធ្ងន់ធ្ងរ នឹងបង្កអោយដើមងាប់ទាំងស្រុង ឬងាប់តែម្ខាង ចៀរគ្មានទឹកជ័រ
<u>គ) ដើមកំពុងចៀរជ័រធម្មតា ឃើញមានស្នាមស្ងួតជ័រជាកំណាត់ខ្លីៗមួយចំនួនលើមុខចៀរ។ ស្នាមស្ងួតជ័រ នឹងរីកពលដាលយ៉ាងឆាប់រហ័ស បន្ទាប់មកស្ងួតពេញមុខចៀរ ហើយដើមកៅស៊ូនឹងស្ងួតជ័រទាំងស្រុង</u>
ឃ) ចំឡើយទាំង៣ខាងលើ ត្រូវទាំងអស់